# ការធ្វើពង្រាងច្បាប់

## ក) សេចក្តីផ្តើម

ការធ្វើពង្រាងច្បាប់ គឺភារកិច្ចដ៏លំបាកមួយ ។ ការធ្វើពង្រាងច្បាប់អាចប្រៀបបានទៅនឹងការងាររបស់វិស្វករដែលធ្វើម៉ាស៊ីនដ៏ធំមួយ ។ ការងារនេះត្រូវការការគូរប្លង់ និងការរៀបចំសេចក្តីលំអិតផ្នែកបច្ចេកទេសជាច្រើន រហូតដល់ម៉ាស៊ីននេះអាចដំណើរការបានស្រួល និងល្អប្រសើរ ។ ប្រសិនបើគ្រប់ផ្នែករបស់ម៉ាស៊ីននេះមិនត្រូវគ្នា ឬប្រសិនបើមុខងាររបស់ម៉ាស៊ីននេះមិនត្រូវបានគេកំណត់ច្បាស់លាស់ ឬប្រសិនបើប្លង់ស្ថាបនាម៉ាស៊ីននេះមិនគោរពតាមគោលការណ៍មូលដ្ឋាននៃធម្មជាតិ និងរូបវិទ្យាទេនោះ ម៉ាស៊ីននេះនឹងទទួលរងនូវភាពតានតឹងផ្នែកខាងក្នុង និងខាងក្រៅ ហើយនឹងខូចជាមិនខាន ។

ដូច្នេះ មានតែអ្នកជំនាញច្បាប់ដែលបានទទួលការបណ្តុះបណ្តាល និងមានបទពិសោធន៍ប៉ុណ្ណោះ ទើបមានសមត្ថភាពតាក់តែងច្បាប់ថ្មីមួយដែលដំណើរការល្អបាន ។ ដើម្បីបង្រួមកុំឱ្យស្ថាប័ននីតិកម្មកម្ពុជាពឹងផ្អែកលើអ្នកជំនាញបរទេសច្រើនពេកនៅក្នុងវិស័យនេះ និងដើម្បីផ្តល់អំណាចដល់គណៈវិនិច្ឆ័យកម្ពុជាក្នុងការធ្វើពង្រាងច្បាប់ទាំងឡាយនៃប្រទេសរបស់ពួកគេនោះ វគ្គបណ្តុះបណ្តាលស្តីពីការធ្វើពង្រាងច្បាប់មួយចំនួន ត្រូវបានរៀបចំឡើងហើយ **សៀវភៅមួយចំនួនស្តីពីការធ្វើពង្រាងច្បាប់នៅប្រទេសកម្ពុជា** ត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំកន្លងទៅនេះ[២០] ។

អត្ថបទខាងក្រោមនិយាយអំពីការសិក្សាលើសៀវភៅទាំងនេះ និង អំពីការចូលរួមនៅក្នុងវគ្គបណ្តុះ-បណ្តាលស្តីពីការធ្វើពង្រាងច្បាប់ឯកទេសទាំងនោះ ដើម្បីទទួលបាននូវចំណេះដឹងជំនាញអំពីវិធីធ្វើពង្រាងច្បាប់ ។

សៀវភៅនេះ ចង់ផ្តល់នូវទស្សនៈរួមមួយទៅលើឧបសគ្គធំៗនៅក្នុងការធ្វើពង្រាងច្បាប់ ដើម្បីផ្តល់ចក្ខុវិស័យមួយចំនួននៅក្នុងកំហុសដ៏សាមញ្ញបំផុតដែលគេតែងតែបង្កើតឡើងនាពេលបច្ចុប្បន្ន នៅពេលធ្វើពង្រាងច្បាប់នានា ។ ដូច្នេះ អត្ថបទនេះ មានបំណងឱ្យ**សមាជិកសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាយ៉ាងហោចណាស់បានបញ្ចេញមតិ ទៅលើពង្រាងច្បាប់ថ្មីៗ** ក្នុងលក្ខណៈសម្របសម្រួល ជ្រាលជ្រៅ និងរិះគន់មួយ និងដើម្បីរិះរកសំណើមួយចំនួនសំរាប់ការកែលំអ ។ ចំណុចនេះរាប់បញ្ចូលទាំងការយល់ដឹងជាមូលដ្ឋានលើបញ្ហា និងឧបសគ្គនានាពាក់ព័ន្ធនឹងផ្នែក ផ្សេងៗរបស់ច្បាប់ និងមុខងាររបស់ផ្នែកច្បាប់ទាំងនេះ ។

## ខ) ខ្លឹមសារជាមូលដ្ឋាននៃច្បាប់

ដូចបានរៀបរាប់នៅក្នុងជំពូកនិយាយអំពីនីតិរដ្ឋរួចមកហើយ មុខងារចំបងរបស់ច្បាប់ គឺដើម្បីដោះស្រាយបញ្ហាដែលកើតចេញពីសិទ្ធិមនុស្សនៃសមាជិកផ្សេងៗដែលមានទំនាស់នៅក្នុងសង្គមមួយ ។ ដើម្បីផ្តល់នូវដំណោះស្រាយទំនាស់មួយដែលអាចអនុវត្តបាន ច្បាប់ត្រូវតែផ្តល់នូវចម្លើយចំពោះសំនួរជាមូលដ្ឋានទាំងបួននេះ :

---

[២០] សូមមើល មូលនិធិ ខុនរ៉ាត់ អាដេណូអឺរ (Konrad Adenauer Foundation): "សៀវភៅស្តីពីការធ្វើពង្រាងច្បាប់ និងនីតិកម្ម" និង ប៉ាទ្រិសៀ បារ (Patricia Baars)"សេចក្តីណែនាំជាក់ស្តែងស្តីពីការតាក់តែងច្បាប់" (២០០១) (ភាសាអង់គ្លេស និងភាសាខ្មែរ) ។